ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៦

ជូនចំពោះ មាតាបិតា/អាណាព្យាបាលៈ

សូមជួយខ្ញុំឲ្យបានទៅជាដៃគូជាមួយលោកអ្នក ក្នុងការអប់រំកូនរបស់លោកអ្នក។ ខ្ញុំចង់ធ្វើអ្វីៗគ្រប់យ៉ាងដើម្បីឲ្យកូនរបស់លោកអ្នកនៅក្នុងឆ្នាំសិក្សានេះ មានការរីកចម្រើននូវចំណេះដឹងក្នុងការអាន និងការសរសេរ។ ក្នុងនាមជាគ្រូ ខ្ញុំចង់ផ្តល់ឲ្យកូនរបស់លោកអ្នកនូវការសិក្សាដែលមានប្រយោជន៍ក្នុងជីវិត។

ខ្ញុំដឹងថាការបង្ហាត់បង្រៀនរបស់ខ្ញុំ ត្រូវចាប់ផ្តើមជាមួយអ្វីដែលអាចធ្វើឲ្យកូនរបស់លោកអ្នកយល់ថាពួកគេទទួលការជួយគាំទ្រនៅក្នុងថ្នាក់រៀន។ ដើម្បីធ្វើយ៉ាងនេះទៅបាន ខ្ញុំចង់ស្វែងយល់ពីកូនរបស់លោកអ្នក ដើម្បីឲ្យខ្ញុំអាចបង្កើតការសហការក្នុងការសិក្សា ទៅតាមលក្ខណៈពិសេសរបស់សិស្សម្នាក់ៗ ទៅតាម បែបផែននៃការសិក្សា ចំណាប់អារម្មណ៍ និងសេចក្តីសង្ឃឹមសម្រាប់អានាគតរបស់ពួកគេរៀងៗខ្លួន។

តើលោកអ្នកអាចជួយខ្ញុំឲ្យដឹងពីកូនរបស់លោកអ្នកបន្ថែមទៀតបានដែរឬទេ ដោយចំណាយពេលបន្តិចដើម្បីបំពេញ ការស្ទង់មតិរបស់មាតាបិតានៅថ្ងៃចូលរៀនដំបូង? តើកូនលោកអ្នកពូកែអ្វីខ្លះ? តើវិធីណាដែលអាចជួយឲ្យពួកគេរៀនបានល្អបំផុត? តើអ្វីទៅដែលជា គោលបំណង និង ការចង់បាន សម្រាប់អនាគតរបស់កូនលោកអ្នក? តើកូនរបស់លោកអ្នកមានចំណាប់អារម្មណ៍ទៅលើអ្វីដែរ? តើលោកអ្នកចង់ឲ្យខ្ញុំដឹងអ្វីអំពីកូនរបស់លោកអ្នក? ខ្ញុំចង់ដឹងពីវិធីដែលកូនលោកអ្នក គិត និង រៀនបានល្អ ដើម្បីខ្ញុំអាចជួយពួកគេឲ្យទទួលបានជោគជ័យនៅឆ្នាំសិក្សានេះ។

សូមទាក់ទងមកខ្ញុំនៅពេលណាក៏បានក្នុងឆ្នាំសិក្សានេះ ដើម្បីពិភាក្សាគ្នាអំពីការរីកចម្រើនរបស់កូនលោកអ្នក។ វិធីទាក់ទងមកខ្ញុំដែល ងាយស្រួល និង រហ័សបំផុត គឺតាមរយៈអ៊ីមែល sbeverly@philasd.org។ នៅចុងឆ្នាំនេះ យើងអាចទាក់ទងគ្នាតាមការប្រើ Google Classroom និង/ឬ Class Dojo។ នឹងមានព័ត៌មានបន្ថែមក្នុងពេលឆាប់ៗនេះ!

ខ្ញុំរង់ចាំអានការឆ្លើយតបរបស់លោកអ្នក នៅក្នុងការស្ទង់មតិរបស់មាតាបិតានៅថ្ងៃចូលរៀនដំបូងនេះ!

ដោយសេចក្តីស្ម័គ្រស្មោះ

Mrs. Beverly
គ្រូបង្រៀនសិស្សថ្នាក់ទី៧ ផ្នែក ការអាន និង ការសរសេរ
សាលា លី (Lea)

ការស្ទង់មតិរបស់មាតាបិតានៅថ្ងៃចូលរៀនដំបូងៗ សូមប្រគល់លិខិតនេះទៅឲ្យ MRS. BEVERLY ឲ្យទាន់ ថ្ងៃព្រហស្បតិ៍ ទី៨ ខែកញ្ញា។ សូមឆ្លើយសំណួរខាងក្រោមនេះជាភាសាដែលងាយស្រួលសរសេរសម្រាប់លោកអ្នក។ ខ្ញុំចង់ឲ្យការស្ទង់មតិនេះមានការងាយស្រួលចំពោះលោកអ្នក!

ខ្ញុំបានអានសេចក្តីសង្ខេបអំពីការ «ស្វាគមន៍ថ្នាក់អក្សរសិល្ប៍អង់គ្លេសសម្រាប់សិស្សថ្នាក់ទី៧» របស់ អ្នកគ្រូ Beverly។ ក្នុងនាមជាសិស្ស ខ្ញុំនឹងខិតខំសិក្សាឲ្យបានតាមការចង់បានរបស់ថ្នាក់យើង។ ក្នុងនាមជា មាតាបិតា/អាណាព្យាបាល ខ្ញុំយល់ព្រមជួយគាំទ្រកូនខ្ញុំឲ្យធ្វើតាមការចង់បានរបស់ថ្នាក់រៀន។ ខ្ញុំដឹងអំពីការទទួលខុសត្រូវចំពោះ កិច្ចការដែលគ្រូឲ្យយកមកធ្វើនៅផ្ទះ និង កិច្ចការនៅសាលា របស់កូនខ្ញុំ។

---

ឈ្មោះសិស្ស ____________________________________________

ហត្ថលេខារបស់សិស្ស ____________________________________________

ឈ្មោះរបស់ មាតាបិតា/អាណាព្យាបាល____________________________________________

ជាប់សាច់ញាតិនឹងសិស្សជា ____________________________________________

ហត្ថលេខារបស់ មាតាបិតា/អាណាព្យាបាល____________________________________________

លេខទូរស័ព្ទរបស់ មាតាបិតា/អាណាព្យាបាល____________________________________________

អ៊ីមែលរបស់ មាតាបិតា/អាណាព្យាបាល____________________________________________

តើនិយាយភាសាអ្វីនៅផ្ទះ? ____________________________________________

តើកូនលោកអ្នកមានអ៊ិនធ័រណិតនៅផ្ទះឬទេ? ____________________________________________

១. សូមរៀបរាប់ពីភាពខ្លាំងពូកែរបស់ក្មេង។ តើពួកគេពូកែខាងអ្វី? មូលហេតុអ្វី?

____________________________________________
____________________________________________
____________________________________________
____________________________________________

២. តើវិធីណាដែលអាចជួយពួកគេឲ្យរៀនបានល្អបំផុត? តើពួកគេត្រូវការអ្វីដើម្បីទទួលបានជោគជ័យ និង ហេតុអ្វី?

____________________________________________
____________________________________________
____________________________________________
____________________________________________

៣. តើអ្វីទៅដែលជា គោលបំណង និង ការចង់បាន សម្រាប់អនាគតរបស់កូនលោកអ្នក?

____________________________________________
____________________________________________
____________________________________________
____________________________________________

៤. តើកូនលោកអ្នកចង់រៀនអ្វីបន្ថែមទៀត? តើពួកគេចូលចិត្តធ្វើអ្វីជាការកម្សាន្ត?

____________________________________________
____________________________________________
____________________________________________
____________________________________________

៥. តើលោកអ្នកចង់ឲ្យខ្ញុំដឹងអ្វីបន្ថែមទៀតអំពី លោកអ្នក ក្រុមគ្រួសាររបស់លោកអ្នក ឬ កូនរបស់លោកអ្នក?

____________________________________________
____________________________________________
____________________________________________
____________________________________________